# ប្រវត្តិវិទ្យា

## សម័យសង្គមរាស្ត្រនិយម

**(1955-1970)**

ប្រទេសកម្ពុជាសម័យសង្គមរាស្ត្រនិយមនៅក្រោមការដឹកនាំរបស់ព្រះបាទ នរោត្តមសីហនុ។ ព្រះអង្គទ្រង់បានប្រសូត្រនៅថ្ងៃទី 31 ខែ តុលា ឆ្នាំ 1922 ជាព្រះរាជបុត្ររបស់ព្រះបាទ នរោត្តម សុរាម្រឹត និង ព្រះមហាក្សត្រី យានី ស៊ីសុវត្ថិមុនីវង្សកុសុមៈនារីរត្ន័សិរីវឌ្ឍនា។

### ♦ នយោបាយក្នុងប្រទេស

- នៅថ្ងៃទី 3 ខែ មិនា ឆ្នាំ 1955 ព្រះបាទ នរោត្តមសីហនុ បានដាក់រាជ្យសម្បត្តិ ក្នុងរាជ្យបំនង ផ្សារភ្ជាប់ទំនាក់ទំនងទៅនឹង ប្រជារាស្ត្រ។
- នៅថ្ងៃទី 24 ខែ មិនា ឆ្នាំ 1955 ព្រះអង្គបានបង្កើតចលនាមហាជនដ៍ទូលំទូលាយមួយមាន ឈ្មោះថា “សង្គមរាស្ត្រនិយម”។
- ចលនាសង្គមរាស្ត្រនិយមបានទទួលជោគជ័យយ៉ាងធំធេងក្នុងការបោះឆ្នោតនៅឆ្នាំ 1955 ដែលមានសម្លេងគាំទ្រ 83%។
- នៅខែ ធ្នូ 1957 សមាជជាតិត្រូវដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

### ♦ នយោបាយក្រៅប្រទេស

- នៅថ្ងៃទី 14 ធ្នូ 1955 ប្រទេសកម្ពុជាត្រូវបានចូលជាសមាជិកពេញសិទ្ធរបស់អង្គការសហប្រជាជាតិ។
- ព្រះបាទ នរោត្តមសីហនុ ប្រកាន់ខ្ជាប់នូវនយោបាយអព្យាក្រឹត្យ និង មិនចូលបក្សសម្ព័ន្ធ ហើយរួមរស់ដោយសន្តិសហវិជ្ជមានជាមួយប្រទេសជិតខាង។
- ព្រះអង្គបានយាងទៅចូលរួមសន្និសិទកំពូល អាហ្វ្រិកអាស៊ី លើកទី1 នៅទីក្រុងបានឌុង ប្រទេសឥណ្ឌូនេស៊ី ដើម្បីពង្រឹង និង ពង្រីកនយោបាយក្រៅប្រទេស។
- នៅឆ្នាំ 1956 នៅទីក្រុង ប្រ៊ីយ៉ូនី ប្រទេសយូហ្គោស្លាវី ព្រះអង្គបានឡាយព្រះហត្ថលេខា ជាមួយប្រធានាធិបតី នៃប្រទេសផ្សេងៗលើរដ្ឋធម្មនុញ្ញនៃចលនាមិនចូលបក្សសម្ព័ន្ធ។
- នៅឆ្នាំ 1961 ព្រះអង្គបានយាងចូលក្នុងសន្និសិទនៃប្រទេសមិនចូលបក្សសម្ព័ន្ធនៅទីក្រុង បែលក្រាត ប្រទេស យូហ្គោស្លាវី។
- ថ្ងៃទី 23 ខែ តុលា ឆ្នាំ 1961 រាជរដ្ឋាភិបាលកម្ពុជាបានបង្ខំផ្តាច់ទំនាក់ទំនងខាងការទូតជាបណ្តោះអាសន្នជាមួយថៃ។
- ថ្ងៃទី 27 ខែ សីហា ឆ្នាំ1963 កាត់ផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាមខាងត្បូង។

### ♦ វិស័យកសិកម្ម

ព្រះបាទ នរោត្តមសីហនុ យកព្រះទ័យទុកដាក់លើគោលនយោបាយពង្រីកដីកសិកម្ម ការជ្រើសរើសពូជ ការប្រើដីធម្មជាតិគួបផ្សំដីគីមី ការធ្វើនយោបាយទឹក ការពង្រីកផ្នែកគមនាគមន៍ និង ទេសចរណ៍ធ្វើឲ្យសេដ្ឋកិច្ចរីកចំរើនខ្លាំង។

### ♦ វិស័យគមនាគមន៍

- ឆ្នាំ 1955 ពង្រីកកំពុងផែនៅភ្នំពេញ និង បានកសាងកំពុងផែមួយទៀតនៅ ក្រុងព្រះសីហនុ។
- ឆ្នាំ 1958 ពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុង និង កសាងអាកាសយានដ្ឋានអន្តរជាតិ សៀមរាប មួយទៀត។
- ឆ្នាំ 1960 បានកសាងផ្លូវរថភ្លើងខ្សែទី2 ចេញពីភ្នំពេញ ទៅ ក្រុងព្រះសីហនុ និង កសាងស្ពានជ្រោយចង្វាឆ្លងទន្លេសាប។

### ♦ វិស័យឧស្សាហកម្ម

រាជរដ្ឋាភិបាលបានជំរុញឲ្យកសាងរោងចក្រមួយចំនួនដូចជា រោងចក្រវាយនភណ្ឌ, ក្តារបន្ទះ, ក្រដាស, ស៊ីម៉ងត៍, បារក្រចៅ, ស្ករស, កែវ, កៅស៊ូ, ដំឡើងត្រាក់ទ័រ, ចំរាញ់ប្រេងកាត, ស្រាបៀ និង ស្ថាបនាទំនប់វារីអគ្គិសនីនៅកំពុងស្ពឺ។

### ♦ វិស័យវប្បធម៌

រាជរដ្ឋាភិបាលបានពង្រីកវិស័យវប្បធម៌ ដោយកសាងអាគារសិក្សា បណ្តុះបណ្តាល បុគ្គលិកសិក្សាគ្រប់ភូមិសិក្សា។

នៅថ្ងៃទី 13 មករា 1960 សកលវិទ្យាល័យភ្នំពេញត្រូវបានបង្កើតឡើង និង មានមហាវិទ្យាល័យជាច្រើនទៀត។

រៀបរៀងដោយ អ៊ុក ភារិទ្ធ